# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ក្នុងនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងខេត្តកណ្តាល

**សាលាដំបូងខេត្តកណ្តាល**

**សំណុំរឿងរដ្ឋប្បវេណី**
លេខ: ០៩៧
ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣
**សាលក្រមរដ្ឋប្បវេណី**
លេខ: **១០** "ឃ"
ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ៖

**<u>ចៅក្រមជំនុំជម្រះ</u>**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

**<u>ក្រឡាបញ្ជី</u>**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

-រាំងដើមចោទឈ្មោះ [redacted] ខៀវ ភេទស្រី កើតថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៥ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០០១៤១៩២(០១) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ [redacted]។

ដោយមានមេធាវី [redacted] អត្តលេខ ១៧៨១, មេធាវី [redacted] អត្តលេខ ១៣១២ និងមេធាវី [redacted] អត្តលេខ ១៧២២ ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ។

-ចុងចម្លើយឈ្មោះ [redacted] នាម ភេទស្រី កើតថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៤៩ ជាតិខ្មែរ មានអាសយដ្ឋាន [redacted]។ (ស្លាប់)

-អ្នកទទួលបន្តនីតិវិធីនៃបណ្តឹងរបស់ចុងចម្លើយ ឈ្មោះ [redacted] មុយ ភេទស្រី កើតថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៦ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២០៦៣០៩១១(០១) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ មានអាសយដ្ឋានស្ថិតនៅ [redacted] (ត្រូវជាកូនបង្កើតរបស់ឈ្មោះ [redacted] នាម។

ដោយមានមេធាវី [redacted] អត្តលេខ ២៥៦៦T ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] មុយ។

<u>ដែលមានកម្មវត្ថុ</u> សុំបញ្ជាក់អត្ថិភាពនៃសិទ្ធិកម្មសិទ្ធិ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ខៀវ។

-បានឃើញ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ $G_8$ 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២។

-បានឃើញ លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៧៥១ សរធ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់មេឃុំសំរោងធំ។

-បានឃើញ លិខិតបញ្ជាក់ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់មេភូមិជ័យឧត្តម។

-បានឃើញ លិខិតបញ្ជាក់ប្រវត្តិដីលេខ ១០៨៨ សរធ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ របស់មេភូមិជ័យឧត្តម។

-បានឃើញ សៀវភៅស្នាក់នៅរបស់ឈ្មោះ ខូវ នាម។

-បានឃើញ លិខិតបញ្ជាក់មរណភាព ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ ខូវ នាម។

-បានឃើញ លិខិតបញ្ជាក់ទាយាទ លេខ ០៦១ ល.ប ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣។

-បានឃើញ លិខិតទទួលស្គាល់ការទាមទារ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ឈ្មោះ លី មុយ។

## អង្គហេតុ និងចំណុចវិវាទ

១) **ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖**

១.១.បញ្ជាក់ថាដើមចោទឈ្មោះ [redacted] ខៀវ មានអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G8 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានទំហំសរុប ៤៨១០ ម២ (បួនពាន់ប្រាំបីរយដប់ម៉ែត្រក្រឡាការ៉េ) មានទទឹង ៣៧ ម៉ែត្រ និង បណ្ដោយ ១៣០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវវត្ត ខាងត្បូងទល់នឹង [redacted] ស៊ីម ខាងកើតទល់នឹង ផ្លូវជាតិ ខាងលិចទល់នឹង វត្តជ័យឧត្តម។

១.២. បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] ខៀវ ធ្វើនីតិវិធីចុះបញ្ជីដីធ្លីជាកម្មសិទ្ធិនូវអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G8 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានទំហំសរុប ៤៨១០ ម២ (បួនពាន់ប្រាំបីរយដប់ម៉ែត្រក្រឡាការ៉េ) មានទទឹង ៣៧ ម៉ែត្រ និង បណ្ដោយ ១៣០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវវត្ត ខាងត្បូងទល់នឹង [redacted] ស៊ីម ខាងកើតទល់នឹង ផ្លូវជាតិ ខាងលិចទល់នឹង វត្តជ័យឧត្តម នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល និងអាជ្ញាធរពាក់ព័ន្ធ។

១.៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] ខៀវ។

២) **ការពន្យល់ត្រួសៗអំពីរឿងក្ដី៖**

យោងតាមពាក្យបណ្ដឹងចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ របស់ដើមចោទ បានបញ្ជាក់ថា នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ ដើមចោទឈ្មោះ [redacted] ខៀវ បានទិញដីមួយកន្លែងមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G8 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានទំហំសរុប ៤៨១០ ម២ (បួនពាន់ប្រាំបីរយដប់ម៉ែត្រក្រឡាការ៉េ) មានទទឹង ៣៧ ម៉ែត្រ និង បណ្ដោយ ១៣០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវវត្ត ខាងត្បូងទល់នឹង [redacted] ស៊ីម ខាងកើតទល់នឹង ផ្លូវជាតិ ខាងលិចទល់នឹង វត្តជ័យឧត្តម ពីចុងចម្លើយឈ្មោះ [redacted] នាម ប៉ុន្តែដើមចោទខកខានពុំបានធ្វើប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុទេ ដោយសារតែដីនៅតំបន់នោះក្រសួងដែនដីនគរូបនីយកម្មពុំទាន់ចុះធ្វើប្លង់ជាប្រព័ន្ធជូនពលរដ្ឋនៅឡើយទេ។ ជាងនេះទៅទៀត ដើមចោទ និងចុងចម្លើយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីត្រឹមឃុំប៉ុណ្ណោះ។ រហូតមកដល់ពេលនេះដើមចោទមានបំណងធ្វើប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ ប៉ុន្តែពុំអាចធ្វើបានទេ ដោយសារតែចុងចម្លើយបានទទួលមរណៈ ហើយដើមចោទមិនមានឯកសារគ្រប់គ្រាន់ដើម្បីបំពេញនីតិវិធីចុះបញ្ជីដីធ្លីនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល និងអាជ្ញាធរពាក់ព័ន្ធ។ ហេតុនេះ ទើបដើមចោទដាក់ពាក្យបណ្ដឹងនេះតែម្ដង។

៣) **ការអះអាងរបស់ភាគី៖**

-សេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ថា៖ នាងខ្ញុំស្នើសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

១.បញ្ជាក់ថាដើមចោទឈ្មោះ [redacted] ខៀវ មានអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G8 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានទំហំសរុប ៤៨១០ ម២ (បួនពាន់ប្រាំបីរយដប់ម៉ែត្រ

ក្រឡាការ៉េ) មានទទឹង ៣៧ ម៉ែត្រ និង បណ្តោយ ១៣០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវវត្ត ខាងត្បូងទល់នឹង [redacted] ស៊ីម ខាងកើតទល់នឹង ផ្លូវជាតិ ខាងលិចទល់នឹង វត្តជ័យឧត្តម។

២.បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] ខៀវ ធ្វើនីតិវិធីចុះបញ្ជីដីធ្លីជាកម្មសិទ្ធិនូវអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G8 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានទំហំសរុប ៤៨១០ ម២ (បួនពាន់ប្រាំបីរយដប់ម៉ែត្រក្រឡាការ៉េ) មានទទឹង ៣៧ ម៉ែត្រ និង បណ្តោយ ១៣០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវវត្ត ខាងត្បូងទល់នឹង [redacted] ស៊ីម ខាងកើតទល់នឹង ផ្លូវជាតិ ខាងលិចទល់នឹង វត្តជ័យឧត្តម នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល និងអាជ្ញាធរពាក់ព័ន្ធ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] ខៀវ។

ចំពោះអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺនៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ ដើមចោទឈ្មោះ ទា ខៀវ បានទិញដីមួយកន្លែងមាន ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G8 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានទំហំសរុប ៤៨១០ ម២ (បួនពាន់ប្រាំបីរយដប់ម៉ែត្រក្រឡាការ៉េ) មានទទឹង ៣៧ ម៉ែត្រ និង បណ្តោយ ១៣០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវវត្ត ខាងត្បូងទល់នឹង [redacted] ស៊ីម ខាងកើតទល់នឹង ផ្លូវជាតិ ខាងលិចទល់នឹង វត្តជ័យឧត្តម ពីចុងចម្លើយឈ្មោះ ខូវ នាម ប៉ុន្តែដើមចោទខកខានពុំបានធ្វើប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុទេ ដោយសារតែដីនៅតំបន់នោះក្រសួងដែនដីនគរូបនីយកម្មពុំទាន់ចុះធ្វើប្លង់ជាប្រព័ន្ធជូនពលរដ្ឋនៅឡើយទេ។ ជាងនេះទៅទៀត ដើមចោទ និងចុងចម្លើយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីត្រឹមឃុំប៉ុណ្ណោះ។ រហូតមកដល់ពេលនេះដើមចោទមានបំណងធ្វើប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ ប៉ុន្តែពុំអាចធ្វើបានទេ ដោយសារតែចុងចម្លើយបានទទួលមរណៈ ហើយដើមចោទមិនមានឯកសារគ្រប់គ្រាន់ដើម្បីបំពេញនីតិវិធីចុះបញ្ជីដីធ្លីនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល និងអាជ្ញាធរពាក់ព័ន្ធ។ ហេតុនេះ ទើបដើមចោទដាក់ពាក្យបណ្តឹងនេះតែម្តង។ ប្រាក់ប្រដាប់ក្តី រឿងក្តីនេះគប្បីឲ្យដើមចោទឈ្មោះ [redacted] ខៀវ ជាអ្នកទទួលបន្ទុក យោងមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំពោះអង្គច្បាប់នាងខ្ញុំសូមបញ្ជាក់ជូនតុលាការថា កិច្ចសន្យាទិញលក់រវាងដើមចោទឈ្មោះ [redacted] ខៀវ និងចុងចម្លើយឈ្មោះ [redacted] នាម ត្រឹមត្រូវតាមច្បាប់ ដោយអ្នកលក់បានផ្ទេរកម្មសិទ្ធិឱ្យអ្នកទិញ ហើយអ្នកទិញបានបង់ប្រាក់គ្រប់ចំនួនឱ្យទៅអ្នកលក់ ព្រមទាំងបានធ្វើកិច្ចសន្យាទិញលក់នេះ ក្នុងទម្រង់យថាភូតទៀតផងដែរ ស្របតាមមាត្រា ៥១៥ និងមាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី។ ចំណុចទី២ ចុងចម្លើយឈ្មោះ [redacted] នាម បានទទួលមរណភាព។ ឈ្មោះ [redacted] មុយ ដែលជាកូនតែម្នាក់គត់របស់ឈ្មោះ [redacted] នាម បានទទួលបន្តនីតិវិធី បានឆ្លើយទទួលស្គាល់នូវអង្គហេតុ និងការទាមទាររបស់ដើមចោទ។ យោងតាមមាត្រា ២២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្នើសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារតាមការទាមទាររបស់ដើមចោទ។ ចំណុចទី៣ សុំឱ្យតុលាការសម្រេចឱ្យដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តីយោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ នាងខ្ញុំសំណូមពរតុលាការសម្រេចតាមការទាមទារខាងលើដោយក្តីអនុគ្រោះ។

-មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] មុយ ដែលត្រូវជាកូនបង្កើតរបស់ចុងចម្លើយឈ្មោះ [redacted] នាម បានថ្លែងការណ៍ថា កូនក្តីរបស់ខ្ញុំបាទសូមធ្វើការទទួលស្គាល់ថា ដីដែលជាកម្មវត្ថុនៅក្នុងសំណុំរឿងនេះ ម្តាយរបស់គាត់ ពិតជាបានលក់ដីនោះឱ្យឈ្មោះ [redacted] ខៀវ ពិតប្រាកដមែន ហើយមកដល់ពេលនេះកូនក្តីរបស់ខ្ញុំបាទមិនធ្វើការទាមទារអ្វីទេ និងទទួលស្គាល់ការទាមទារទាំងស្រុងរបស់ឈ្មោះ [redacted] ខៀវ។ ខ្ញុំបាទសំណូមពរសុំឱ្យតុលាការពិចារណាសម្រេចតាមនីតិវិធីច្បាប់។



Scanned with CamScanner

៤) ចំណុចវិវាទ:

- នៅក្នុងសំណុំរឿងនេះ មិនមានចំណុចវិវាទនោះទេ។

## សំអាងហេតុ

-តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ៖

១/. តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ថា នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ ដើមចោទឈ្មោះ [redacted] ខៀវ បានទិញដីមួយកន្លែងមាន ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G8 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានទំហំសរុប ៤៨១០ ម២ (បួនពាន់ប្រាំបីរយដប់ម៉ែត្រក្រឡាការ៉េ) មានទទឹង ៣៧ ម៉ែត្រ និង បណ្តោយ ១៣០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវវត្ត ខាងត្បូងទល់នឹង [redacted] ស៊ុម ខាងកើតទល់នឹង ផ្លូវជាតិ ខាងលិចទល់នឹង វត្តជ័យឧត្តម ពីចុងចម្លើយឈ្មោះ [redacted] នាម ប៉ុន្តែដើមចោទខកខាន់ពុំបានធ្វើប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុទេ ដោយសារតែដីនៅតំបន់នោះក្រសួងដែនដីនគរូបនីយកម្មពុំទាន់ចុះធ្វើប្លង់ជាប្រព័ន្ធជូនពលរដ្ឋនៅឡើយទេ។ ជាងនេះទៅទៀត ដើមចោទ និងចុងចម្លើយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីត្រឹមឃុំប៉ុណ្ណោះ។ រហូតមកដល់ពេលនេះដើមចោទមានបំណងធ្វើប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ ប៉ុន្តែពុំអាចធ្វើបានទេ ដោយសារតែចុងចម្លើយបានទទួលមរណៈ ហើយដើមចោទមិនមានឯកសារគ្រប់គ្រាន់ដើម្បីបំពេញនីតិវិធីចុះបញ្ជីដីធ្លីនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល និងអាជ្ញាធរពាក់ព័ន្ធ។

២/. ស្របគ្នានោះដែរ តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] មុយ ដែលជាអ្នកទទួលបន្តនីតិវិធីនៃបណ្តឹងរបស់ចុងចម្លើយឈ្មោះ [redacted] នាម ថា កូនក្តីរបស់ខ្លួនសូមធ្វើការទទួលស្គាល់ថា ដីដែលជាកម្មវត្ថុនៅក្នុងសំណុំរឿងនេះ ម្តាយរបស់គាត់ ពិតជាបានលក់ដីនោះឱ្យឈ្មោះ [redacted] ខៀវ ពិតប្រាកដមែន ហើយមកដល់ពេលនេះ កូនក្តីរបស់ខ្លួនមិនធ្វើការទាមទារអ្វីទេ និងទទួលស្គាល់ការទាមទារទាំងស្រុងរបស់ឈ្មោះ [redacted] ខៀវ ដូចមានបញ្ជាក់នៅក្នុង លិខិតទទួលស្គាល់ការទាមទារ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣។

៣/ តាមការពិនិត្យភស្តុតាងជាឯកសារគឺ លិខិតបញ្ជាក់ទាយាទ លេខ០៦១ ល.ប ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ របស់មេឃុំសំរោងធំ បានបញ្ជាក់ថា ឈ្មោះ [redacted] មុយ ភេទស្រី ពិតជាកូនបង្កើតរបស់ឈ្មោះ [redacted] នាម ប្រាកដមែន។ ដូច្នេះ ឈ្មោះ [redacted] មុយ គឺជាសន្តតិជនរបស់ខ្មោចឈ្មោះ [redacted] នាម ដែលជាបុគ្គលត្រូវទទួលបន្តនីតិវិធីនៃបណ្តឹង តាមមាត្រា ១៧៣ កថាខណ្ឌទី២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤/តាមលិខិតទទួលស្គាល់ការទាមទារ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] មុយ ដែលត្រូវជាកូនបង្កើតតែម្នាក់របស់សពឈ្មោះ [redacted] នាម ដែលបានទទួលមរណភាពក្នុងអំឡុងឆ្នាំ២០១៧ បានទទួលស្គាល់ និងបញ្ជាក់ថា សពឈ្មោះ [redacted] នាម (ត្រូវជាម្តាយ) ពិតជាបានលក់ដីឱ្យទៅឈ្មោះ [redacted] ខៀវ កាលពីអំឡុងឆ្នាំ២០០៨ ប្រាកដមែន និងឈ្មោះ [redacted] មុយ សូមទទួលស្គាល់នូវការទាមទារទាំងស្រុងរបស់ឈ្មោះ [redacted] ខៀវ។

៥/ តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យភាគីដើមចោទ, មេធាវីតំណាងដោយអាណត្តិឱ្យអ្នកទទួលបន្តនីតិវិធីនៃបណ្តឹងរបស់ភាគីចុងចម្លើយ និងការពិនិត្យភស្តុតាងជាឯកសារ មានដូចជា ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $G_8$ 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២, លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៧៥១ សរធ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៨, លិខិតបញ្ជាក់លេខ ១៥៥/០៨ ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ និងលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី១០៨៨ សរធ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ ឃើញថា ឈ្មោះ [redacted] នាម ពិតជាបានព្រមព្រៀងផ្ទេរសិទ្ធិដីមួយកន្លែង ប្រភេទដី អនុផល ស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមានទទឹង ៣៧ម៉ែត្រ បណ្តោយ១៣០ម៉ែត្រ ទំហំ ៤៨១០ ម៉ែត្រ



Scanned with CamScanner

ក្រឡា ឱ្យទៅឈ្មោះ [redacted] ខៀវ ប្រាកដមែន។ ដូច្នេះ ដើមចោទឈ្មោះ [redacted] ខៀវ ពិតជាម្ចាស់កម្មសិទ្ធិ និងបានកំពុងកាន់កាប់ លើអចលនវត្ថុ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $G_8$ 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដែលមានទទឹង ៣៧ម៉ែត្រ បណ្ដោយ១៣០ម៉ែត្រ ទំហំ ៤៨១០ ម៉ែត្រក្រឡា ដែលមានព្រំប្រទល់ខាងជើងទល់នឹង ផ្លូវវត្ត ខាងត្បូងទល់នឹង [redacted] ស៊ីម ខាងកើតទល់នឹង ផ្លូវជាតិ និងខាងលិចទល់នឹង វត្តជ័យឧត្តម ដែលមិនទាន់បានបំពេញនីតិវិធីចុះបញ្ជីដីធ្លី ផ្ទេរឈ្មោះ ផ្ទេរកម្មសិទ្ធិ នៅឡើយ តាមមាត្រា ១៣៣, មាត្រា ១៣៤ និងមាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះ គប្បីតុលាការទទួលស្គាល់លទ្ធកម្មកម្មសិទ្ធិ របស់ដើមចោទឈ្មោះ [redacted] ខៀវ តាមការទាមទារ និងបង្គាប់ឱ្យដើមចោទ ឈ្មោះ [redacted] ខៀវ ធ្វើនីតិវិធីចុះបញ្ជីដីធ្លីផ្ទេរឈ្មោះកម្មសិទ្ធិនូវអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $G_8$ 0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្ដាល និងអាជ្ញាធរពាក់ព័ន្ធ។

៦/.ប្រាក់ប្រដាប់ក្ដី តុលាការ នឹងពិចារណាសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្ដីសម្រេចបញ្ចប់

១-បញ្ជាក់ថាដើមចោទឈ្មោះ [redacted] ខៀវ មានអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $G_8$-0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានទំហំសរុប ៤៨១០ ម² (បួនពាន់ប្រាំបីរយដប់ម៉ែត្រក្រឡាការ៉េ) មានទទឹង ៣៧ ម៉ែត្រ និង បណ្ដោយ ១៣០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវវត្ត ខាងត្បូងទល់នឹង ខូវ ស៊ីម ខាងកើតទល់នឹង ផ្លូវជាតិ ខាងលិចទល់នឹង វត្តជ័យឧត្តម។

២-បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] ខៀវ ធ្វើនីតិវិធីចុះបញ្ជីដីធ្លីជាកម្មសិទ្ធិនូវអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $G_8$-0568 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩២ មានទីតាំងស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានទំហំសរុប ៤៨១០ ម² (បួនពាន់ប្រាំបីរយដប់ម៉ែត្រក្រឡាការ៉េ) មានទទឹង ៣៧ ម៉ែត្រ និង បណ្ដោយ ១៣០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវវត្ត ខាងត្បូងទល់នឹង [redacted] ស៊ីម ខាងកើតទល់នឹង ផ្លូវជាតិ ខាងលិចទល់នឹង វត្តជ័យឧត្តម នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល និងអាជ្ញាធរពាក់ព័ន្ធ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] ខៀវ។

សាលក្រមនេះ បានទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឱ្យគូភាគី។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់។

**ចៅក្រម**

**ហត្ថលេខា និង ត្រា: [redacted]**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៤រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅខេត្តកណ្ដាល, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner